**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៣៩. អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ស្នូលព្រែកទាល់នៃឋបនីយជីវមណ្ឌលបឹងទន្លេសាប ជាតំបន់រាមសារព្រែកទាល់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាមសារ ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧១
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**

អនុក្រឹត្យនេះ មានគោលបំណងកំណត់តំបន់ស្នូលព្រែកទាល់នៃបបនីយជីវមណ្ឌលបឹងទន្លេសាបជាតំបន់រ៉ាមសារព្រែកទាល់ ដើម្បីគ្រប់គ្រង អភិរក្ស និងការពារតំបន់ដីសើមដែលមានសារៈសំខាន់សម្រាប់ជាទីជម្រកធម្មជាតិ កន្លែងរស់នៅ កន្លែងបន្តពូជ និងប្រភពចំណីរបស់ពពួកសត្វស្លាបទឹក សត្វព្រៃ និងមច្ឆជាតិគ្រប់ប្រភេទ រួមទាំងការបង្កើនផលស្តុកត្រីនៅក្នុងតំបន់ ក៏ដូចជា នៅបឹងទន្លេសាបទាំងមូល ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

តំបន់រ៉ាមសារព្រែកទាល់ មានមុខងារសំខាន់ៗ ដូចខាងក្រោម ៖

- គាំទ្រការអភិរក្ស និងការការពារនៃតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ស្របតាមអនុសញ្ញារ៉ាមសារ
- ទប់ស្កាត់ការបាត់បង់ ឬផុតពូជ និងការស្តារឡើងវិញនូវជីវចម្រុះ ធនធានសេនេទិច រុក្ខជាតិ មច្ឆជាតិ និងសត្វព្រៃ ជាពិសេសសត្វស្លាបទឹក និងសត្វព្រៃប្រភេទជិតផុតពូជ ប្រភេទកម្រ និងប្រភេទទទួលរងគ្រោះថ្នាក់ជាសាកល
- ធានាការអភិវឌ្ឍសេដ្ឋកិច្ចសង្គម វប្បធម៌ និងការប្រើប្រាស់ធនធានជីវចម្រុះប្រកបដោយចីរភាព ដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងរួមចំណែកក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល
- គាំទ្រការសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ ការអប់រំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល គម្រោងធ្វើបង្ហាញ និងអង្កេតតាមដាន អំពីការប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការអភិវឌ្ឍ និងអភិរក្សនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតតំបន់។

## ជំពូកទី ២

## ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់នៃតំបន់រ៉ាមសារព្រែកទាល់

**មាត្រា ២.**

តំបន់រ៉ាមសារព្រែកទាល់មានផ្ទៃក្រឡាសរុប ២១.៣៤២ ហិកតា (ម្ភៃមួយពាន់បីរយសែសិបពីរហិកតា) ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រឃុំកោះជីវាំង ស្រុកឯកភ្នំ និងឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានផែនទីមាត្រដ្ឋាន១/១០០.០០០ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ ខ្សែបន្ទាត់ព្រំប្រទល់នៃតំបន់រ៉ាមសារព្រែកទាល់ កំណត់ដោយប្រព័ន្ធខ្សែព្រំបិទចំណុចគោលសំខាន់ៗ មាននិយាមការដូចខាងក្រោម៖

A. ១០៣°៣៦'៣១.២១៩E/ ១៣°១៣'៥.២៦៧N; B.១០៣°៣៧'៣៨.២០៣E/ ១៣°១៣'២២.០៦N;
C. ១០៣°៣៨'៤១.៧៣៤E/ ១៣°១៤'៤.៧៧០N; D.១០៣°៤០'០៩.២៤៣E/ ១៣°១៣'៨.៧៩៦N;
E. ១០៣°៤១'៣៥.១៨១E/ ១៣°១២'២៥.១០៨N; F.១០៣°៤២'១១.៩៤៨E/ ១៣°១០'៧.២៣៦N;

G. ១០៣°៤២'២១.៧០៤E/ ១៣°៦'៥៨.៧៤៦N; H.១០៣°៣៩'២៤.១៨៧E/ ១៣°៥'២១.១៤៥N; I. ១០៣°៣៦'៤៨.១៩៦E/ ១៣°៤'០០.១២៩N; J.១០៣°៣៥'៣០.១៣៧E/ ១៣°៣'៥៦.៣៨៨N; K. ១០៣°៣៣'៤២.៨៤៥E/ ១៣°៦'៥.៣១៩N & L.១០៣°៣៣'៤៩.៨៤០E/ ១៣°៩'១២.៤៩២N។

ចំណុចនិយាមការទាំងនេះ ប្រើប្រាស់សម្រាប់កំណត់ព្រំប្រទល់នៃតំបន់ហ៊មសារព្រែកទាល់តែប៉ុណ្ណោះ ពុំមានឥទ្ធិពលផ្លូវច្បាប់ទៅលើការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ ស្រុក និងខេត្តឡើយ។

**មាត្រា ៣.**

ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រង នៃតំបន់ហ៊មសារព្រែកទាល់ ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ អាចធ្វើទៅបានតាមការចាំបាច់ ក្នុងគោលបំណង ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនាពេលអនាគត។ ការកែប្រែនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៣
## ការគ្រប់គ្រង

**មាត្រា ៤.**

ក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ជាសេនាធិការមានសមត្ថកិច្ច ក្នុងការគ្រប់គ្រង ការពារ និងថែរក្សាតំបន់ហ៊មសារព្រែកទាល់ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ។

**មាត្រា ៥.**

បណ្តាសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ សម្ព័ន្ធសហគមន៍នេសាទ សមាគម ក្រុមហ៊ុនឯកជន អាជ្ញាធរ ក្រុមប្រឹក្សា គណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តការងារនៅមូលដ្ឋាន អាចចូលរួមផ្តល់យោបល់ជូនក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៃតំបន់ហ៊មសារព្រែកទាល់ ដើម្បីជួយធានានិរន្តរភាពនៃធនធានជីវចម្រុះ និងបរិស្ថាននៅក្នុងតំបន់ព្រែកទាល់ ក៏ដូចជា តំបន់ដីសើមបឹងទន្លេសាបទាំងមូល។

**មាត្រា ៦.**

តំបន់ហ៊មសារព្រែកទាល់មានតម្លៃអភិរក្សស្មើនឹងឧទ្យានជាតិ ដែលត្រូវគ្រប់គ្រង ការពារ និងអភិរក្សយ៉ាងហ្មត់ចត់បំផុត ដើម្បីធានាឱ្យបានគង់វង្សនូវប្រព័ន្ធជលសាស្ត្រ ទេសភាព សណ្ឋានដី និងធនធានជីវចម្រុះ រួមទាំង ធនធានសេនេទិច ប្រភេទរុក្ខជាតិ មច្ឆជាតិ និងសត្វព្រៃ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម។

តំបន់ហ៊មសារព្រែកទាល់ អាចអនុញ្ញាតឱ្យមានសកម្មភាពសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដានការប្រែប្រួលបរិស្ថាន និងជីវចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិជាប្រពៃណីនិងការអភិវឌ្ឍអេកូទេសចរណ៍នៅក្នុងតំបន់សហគមន៍គ្រប់គ្រង ដោយមិនអនុញ្ញាតឱ្យមានសកម្មភាពប្រើប្រាស់ ប្រមូលផលអនុផលដែលធ្វើឱ្យរេចរឹល ឬបំផ្លិចបំផ្លាញដល់ជីវចម្រុះឡើយ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមឡាយព្រះហស្តលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទីតំបន់រ៉ាមសារព្រែកទាល់

ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.២៣៨...អនក្រ.បក
ចុះថ្ងៃទី....១២......ខែ...តុលា.......ឆ្នាំ២០១៥...







មាត្រដ្ឋាន 1:100,000

| Code | E | N |
|---|---|---|
| A | 103° 36' 31.219" | 13° 13' 5.267" |
| B | 103° 37' 34.203" | 13° 13' 22.069" |
| C | 103° 38' 41.734" | 13° 14' 4.770" |
| D | 103° 40' 9.243" | 13° 13' 8.796" |
| E | 103° 41' 35.181" | 13° 12' 25.108" |
| F | 103° 42' 11.948" | 13° 10' 7.236" |
| G | 103° 42' 21.704" | 13° 6' 58.746" |
| H | 103° 39' 24.187" | 13° 5' 21.145" |
| I | 103° 36' 48.196" | 13° 4' 0.129" |
| J | 103° 35' 30.137" | 13° 3' 56.388" |
| K | 103° 33' 42.845" | 13° 6' 5.319" |
| L | 103° 33' 49.840" | 13° 9' 12.492" |

